ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ៥ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ខ

មាតិកា

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៨-០២-១៩៩៦	ព្រះរាជក្រឹត្យ រកត/ជស/០២៩៦/០១ តែងតាំងនាយករងខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទី ១	២៨៧
០៨-០២-១៩៩៦	ព្រះរាជក្រឹត្យ រកត/ជស/០២៩៦/០២ តែងតាំងនាយករងខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទី ២	២៨៨

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

០១-០២-១៩៩៦	អនុក្រឹត្យលេខ ០៨ អនក្រ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦	២៩០
០៣-០២-១៩៩៦	អនុក្រឹត្យលេខ ២២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៣១៦
០៥-០២-១៩៩៦	អនុក្រឹត្យលេខ ២៣ អនក្រ.តត តែងតាំងលោក មុត ខៀវ ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២	៣១៧

២ - សេចក្តីសំរេច

០៨-០២-១៩៩៦	សេចក្តីសំរេចលេខ ០៣ សសរ ស្តីពីការបង្កើតក្រុមការងារជាតិសំរាប់ឧត្តមសិក្សា	៣១៨

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

០៦-០២-១៩៩៦ ប្រកាសលេខ ០១០ ប្រក. សហវ. ស្ដីពីការបង្កើតគណៈកម្មការ
ដោះស្រាយវិវាទលើការតវ៉ា អំពីអធិការកិច្ចទំនិញមុនពេលផ្ទុក ៣២០

២ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

០៨-០២-១៩៩៦ ប្រកាសលេខ០៥២ ពណ. បល. ប្រកស្ដីពីការបង្កើតគណៈកម្មការ
ជាតតាំងពិព័រណ៍ពាណិជ្ជកម្មមួយរបស់ក្រសួង ៣២៣

៣ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម
រ៉ែ និង ថាមពល

ប្រកាស

០៥-០២-១៩៩៦ ប្រកាសលេខ ៨១ ឧក. ប្រក អនុញ្ញាតអោយក្រុមហ៊ុនប៉ូតាម៉ុង
ខេមបូឌា (POTAMON CAMBODIA Co LTD) តំណាងដោយ
លោក KENNETH SUEN ជនជាតិខ្មែរ សញ្ជាតិអាមេរិកាំង
បង្កើតរោងចក្រផលិតស្រោមដៃសំរាប់នាំចេញ ៣២៨

៤ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

០២-០២-១៩៩៦ ប្រកាសលេខ ០៣៨/៩៦ ពម. ប្រក អនុញ្ញាតអោយបោះពុម្ព
ផ្សាយសៀវភៅឈ្មោះ (CAMBODIA POCKET GUIDE) ៣២៩

៥ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន
និង កីឡា

ប្រកាស

០៣-០២-១៩៩៦ ប្រកាសលេខ ១១៣ អយក. ប្រក ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ
ភូមិឫស្សី ៣៣១

១៣–០២–១៩៩៦ ប្រកាសលេខ ១១៤ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា វត្តថ្មី ៣៣៣

១៦–០២–១៩៩៦ ប្រកាសលេខ ១១៥ អយក.ប្រក ស្តីពីការបើកវិទ្យាល័យសិរីមង្គល ជាឧបសម្ព័ន្ធរបស់វិទ្យាល័យព្រែកអញ្ចាញ ៣៣៤

១៦–០២–១៩៩៦ ប្រកាសលេខ ១១៦ អយក.ប្រក ស្តីពីការរៀបចំប្រព្រឹត្តិទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាកំរិត ២ ៣៣៦

៦ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

ប្រកាស

១៧–០២–១៩៩៦ ប្រកាសលេខ ០៦៨ ស.ធបឱ ស្តីពីការកំណត់តួនាទីភារកិច្ចរបស់ភ្នាក់ងារត្រួតពិនិត្យឱសថនៅតាមច្រកព្រំដែន ៣៤៣

៧ - ទីស្តីការក្រសួង សង្គមកិច្ចការងារ និង អតីតយុទ្ធជន

ប្រកាស

១៧–០២–១៩៩៦ ប្រកាសលេខ ០០៩ គក.ពក គណៈកម្មការរៀបចំ ទិវាកីឡាជនពិការកម្ពុជា ៣៤៧

៨ - ទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

១៨–០២–១៩៩៦ ប្រកាសលេខ ០១៣ បទ.ប្រក ស្តីពីការប្រើប្រាស់ប្លង់អោយលេខទូរស័ព្ទជាតិ ៣៥៦

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ អកត/ជស/០២៩៦/០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងមន្ត្រី ដូចមានរាយនាមខាងក្រោមនេះ ÷

ថ្នាក់ស្មើ **អគ្គនាយក**

១– លោក **សាយ យាន** ជានាយករងខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទី ១

២– លោក **ម៉ា ជន** ជានាយករងខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទី ១

៣– លោក **តោគ សុវណ្ណរិទ្ធ** ជានាយករងខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទី ១

៤- លោក **គង់ វីរបុល** ជានាយករងខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទី ១

៥- លោក **ឃី ហេង** ជានាយករងខុទ្ទកាល័យ នាយករដ្ឋមន្ត្រីទី ១

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយ បានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ នស/រកត/០២៩៦/០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

សម្រេច

មាត្រា ១ : តែងតាំងមន្ត្រី ដូចមានរាយនាមខាងក្រោមនេះ ÷

ថ្នាក់ស្មើ **អគ្គនាយក**

១- លោក **យី ជន** ជានាយករងខុទ្ទកាល័យសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២

២- លោក **ពិន តាំងសាន** ជានាយករងខុទ្ទកាល័យសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២

៣- លោក **ប្រាក់ វណ្ណឌី** ជានាយករងខុទ្ទកាល័យសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២

៤- លោក **ប៊ុន សំបូរ** ជានាយករងខុទ្ទកាល័យសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២

៥- លោក **សួន សិទ្ធី** ជានាយករងខុទ្ទកាល័យសម្តេចហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយ បានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ០១ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ០៨ អនក្រ

ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋ

សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលបានប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត /១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម នស/រកម/១២៩៥/០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ការគ្រប់គ្រង ឆ្នាំ ១៩៩៦

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ចំណូលថវិកាចរន្តរបស់រដ្ឋ

ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៦

ប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ

ទំព័រ ១/៦ឯកតា :លានរៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ការរាយមុខចំណូល	សរុបរួមចំណូលថវិកា	ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គយនិងរដ្ឋាករ	ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពន្ធដារ	ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ព្រះបរមរាជវាំង	ទីស្តីការគណៈរដ្ឋមន្ត្រីផ្ទាល់	រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	ក្រសួងការពារជាតិ	ក្រសួង [illegible] សន្តិសុខ សាធារណៈ
				សរុបរួមចំណូលថវិកាចរន្តរបស់រដ្ឋ	1 452 300.0	488 760.0	89 910.0	665 370.0	50.0	1 180.0	12 000.0	3 400.0	1 600.0	[illegible]
				សរុបចំណូលជាប្រចាំ	797 500.0	488 760.0	89 910.0	105 70.0	50.0	1 180.0	12 000.0	3 400.0	1 600.0	9 365.0
				ប្រភេទទី ១ : ពន្ធ និងអាករ	577 300.0	487 410.0	89 890.0							
10				ជំពូក១០ : ពន្ធលើផលរបរប្រាក់ចំណេញ និង កំរៃរបរ	25 200.0		25 200.0							
	01			ពន្ធលើប្រាក់បៀវត្ស	2 000.0		2 000.0							
	02			ពន្ធលើប្រាក់ចំណេញរបស់រោងចក្រ និង ពាណិជ្ជកម្ម	20 100.0		20 100.0							
		01		សហគ្រាសសាធារណៈ	2 300.0		2 300.0							
			01	សហគ្រាសមជ្ឈិម	2 300.0		2 300.0							
			02	សហគ្រាសខេត្តនានា										
		02		សហគ្រាសឯកជន	17 800.0		17 800.0							
		03		ពន្ធលើប្រាក់ចំណេញនៃវិជ្ជាជីវៈមិនមែនពាណិជ្ជកម្ម										
	04			ពន្ធលើផលរបរនៃតម្លៃអចលនទ្រព្យ										
	05			ពន្ធលើផលរបរនៃដីធ្លី - ផ្ទះសំបែង	2 100.0		2 100.0							
	06			ពន្ធលើតំលៃលើសអចលនទ្រព្យ										
	07			ពន្ធលើផលរបរកសិកម្ម										
		01		សកម្មភាពព្រៃឈើ										
		02		សកម្មភាពនេសាទ										
		03		អាជីវកម្មកសិកម្មផ្សេងៗទៀត										
	08			ពន្ធពិធីលើដីទំនេរ	1 000.0		1 000.0							
	20			ពន្ធផ្សេងៗទៀតលើផលរបរ-ប្រាក់ចំណេញ និង កំរៃរបរ										
11				ជំពូក១១ : ពន្ធលើបេតិកភ័ណ្ឌ	1 600.0		1 600.0							

ក្រសួងមហាផ្ទៃ សន្តិសុខសាធារណៈ	ក្រសួងមហាផ្ទៃ រដ្ឋបាលទូទៅ	ក្រសួងពត៌មាន	ក្រសួងសាធារណការ និងដឹកជញ្ជូន	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	ក្រសួងយុត្តិធម៌ តុលាការកំពូល	ក្រសួងយុត្តិធម៌ សាលាឧទ្ធរណ៍	ក្រសួងអប់រំ យុវជន និងកីឡា	ក្រសួងពាណិជ្ជកម្ម	ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល	ក្រសួងផែនការ	ក្រសួងសុខាភិបាល	ក្រសួងទេសចរណ៍	ក្រសួងប្រៃសណីយ និង ទូរគមនាគមន៍	ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	ក្រសួងបរិស្ថាន
[illegible]	[illegible] 370.0	610.0	4 400.0	57 270.0	60.0	10.0	220.0	1 495.0	20 220.0	105.0	100.0	6 350.0	80 030.0	350.0	75.0
[illegible] 365.0	[illegible] 370.0	610.0	4 400.0	57 270.0	60.0	10.0	220.0	1 495.0	20 220.0	105.0	100.0	6 350.0	80 030.0	350.0	75.0

ការគ្រប់គ្រង ឆ្នាំ ១៩៩៦

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ចំណូលថវិកាចរន្តរបស់រដ្ឋ

ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៦

ប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង វាក្យខណ្ឌ

ទំព័រ ២/៦ឯកតា :លានរៀល

ជំពូក	ប្រការ	កថាខណ្ឌ	វាក្យខណ្ឌ	ការរាយមុខចំណូល	សរុបរួមចំណូលថវិកា	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គយនិងរដ្ឋាករ	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពន្ធដារ	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ព្រះបរមរាជវាំង	ទីស្ដីការគណៈរដ្ឋមន្ត្រីផ្ទាល់	រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	ក្រសួងការពារជាតិ	ក្រសួងមហាផ្ទៃ សន្តិសុខសាធារណ
12				ជំពូក១២ : ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិ និងសេវាកម្ម	174 400.0	113 310.0	61 090.0							
	01			អាករលើផលរបរ : របបផ្ទៃក្នុង	37 700.0		37 700.0							
		01		សហគ្រាសសាធារណៈ	3 000.0		3 000.0							
			01	សហគ្រាសមជ្ឈិម	3 000.0		3 000.0							
			02	សហគ្រាសខេត្តនានា										
		02		សហគ្រាសឯកជន	34 700.0		34 700.0							
	02			អាករប្រើប្រាស់ : របបនាំចូល	66 400.0	66 400.0								
	03			ពន្ធប៉ាតង់	1 680.0		1 680.0							
	04			អាករពិសេសលើទំនិញមួយចំនួន	62 970.0	46 910.0	16 060.0							
		01		របបផ្ទៃក្នុង	16 060.0		16 060.0							
		02		របបនៃការនាំចូល	46 910.0	46 910.0								
	05			ពន្ធសណ្ឋាគារ	500.0		500.0							
	06			ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ	5 150.0		5 150.0							
	07			អាករស្នាក់នៅ										
13				ជំពូក១៣ : ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស	373 900.0	373 900.0								
	01			ពន្ធ និងអាករគយលើការនាំចូល	354 400.0	354 400.0								
		01		ពន្ធគយពីការនាំចូល	245 600.0	245 600.0								
		02		កំរៃយកមុនលើផលិតផលប្រេងកាត	1 800.0	1 800.0								
		03		កំរៃយកមុនលើការងារគយក្នុងការនាំចូល	5 000.0	5 000.0								
		04		ពន្ធគយលើផលិតផលប្រេងកាត	101 900.0	101 900.0								
		10		ពន្ធ និងអាករគយផ្សេងៗទៀតពីការនាំចូល	100.0	100.0								
	02			អាករពីការនាំចេញ	16 000.0	16 000.0								
		01		អាករគយពីការនាំចេញ	16 000.0	16 000.0								
			01	អាករលើការនាំឈើចេញ	6 000.0	6 000.0								
				[illegible]	[illegible]	[illegible]								

ក្រសួងមហាផ្ទៃ សន្តិសុខសាធារណៈ	ក្រសួងមហាផ្ទៃ រដ្ឋបាលទូទៅ	ក្រសួងពត៌មាន	ក្រសួងសាធារណការ និងដឹកជញ្ជូន	កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	ក្រសួងយុត្តិធម៌ តុលាការកំពូល	ក្រសួងយុត្តិធម៌ សាលាឧទ្ធរណ៍	ក្រសួងអប់រំ យុវជន និងកីឡា	ក្រសួងពាណិជ្ជកម្ម	ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល	ក្រសួងផែនការ	ក្រសួងសុខាភិបាល	ក្រសួងទេសចរណ៍	ប្រៃសណីយ៍ និងទូរគមនាគមន៍	ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	ក្រសួងបរិស្ថាន

[illegible]	[illegible]		និង ដឹក ជញ្ជូន	ប្រមាញ់ និង នេសាទ	[illegible]	[illegible]	និង កីឡា	[illegible]	និង [illegible]		[illegible]	[illegible]	[illegible]	វិចិត្រសិល្បៈ	
[illegible]	9 370.0	610.0	4 400.0	57 270.0		[illegible]	220.0	1 495.0	20 220.0	105.0	100.0	6 350.0	80 030.0	350.0	[illegible]
	3 370.0	205.0	3 710.0	57 270.0				555.0	20 210.0	105.0		6 290.0	30.0	250.0	[illegible]
				12 200.0											
				22 500.0											
	9 260.0	205.0	2 850.0	2 990.0				410.0	19 530.0			6 200.0		250.0	[illegible]
	2 990.0	205.0	740.0	1 040.0					16 100.0			2 600.0		250.0	75
		205.0	650.0	1 040.0					[illegible]			2 600.0		250.0	
	[illegible]		90.0												
			1 390.0	1 900.0				410.0	200.0						
			1 390.0	1 900.0				410.0							
									200.0						
												3 600.0			
			5.0						2695.0						
				50.0											
			500.0												
									500.0						
	[illegible]														
			215						[illegible]						

ចំណូលថវិកានុះទៅរបស់រដ្ឋ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ

 ឯកតាលានរៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ការរាយមុខចំណូល	សរុបរួមចំណូលថវិកា	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គយនិងរដ្ឋាករ	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពន្ធដារ	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ព្រះបរមរាជវាំង	ទីស្តីការគណៈរដ្ឋមន្ត្រី	រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	ក្រសួងការពារជាតិ	ក្រសួងមហាផ្ទៃ សន្តិសុខសាធារណៈ
14				ជំពូក១៤ : ចំណូលសារពើពន្ធផ្សេងៗទៀត	2 200.0	200.0	2 000.0							
	01			ពន្ធតែមប្រិ៍	1 000.0		1 000.0							
	02			ពន្ធលើសារលិខិតស៊ីវិល និង តុលាការ										
	03			អាករលើការសាងសង់										
	04			ការផាកពិន័យ និងទោសបញ្ញត្តិសារពើពន្ធ	1 000.0		1 000.0							
	05			អាករលើយានយន្តនាំចូលដោយផ្ទុយនឹងច្បាប់	200.0	200.0								
	06			អាករព្រលានយន្តហោះ										
	10			ចំណូលសារពើពន្ធផ្សេងៗទៀតតាមមុខពន្ធនានា										
ប្រភេទទី ២ : ចំណូលមិនមែនសារពើពន្ធ					220 200.0	1 350.0	20.0	10 570.0	50.0	1 180.0	12 000.0	3 400.0	1 600.0	9 365.0
20				ជំពូក២០ : ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	121 740.0	500.0		7 125.0		480.0	12 000.0	1 800.0	1 600.0	65.0
	01			ផលនេសាទ	12 200.0									
	02			ផលព្រៃឈើ	22 500.0									
	03			ផលទុន បានមកពីសហគ្រាសសាធារណៈ	55 850.0					480.0	12 000.0		1 600.0	
		01		ការផ្តល់ភាគលាភសហគ្រាស	26 050.0					480.0			1 600.0	
			01	សហគ្រាសមជ្ឈិម	23 000.0					480.0			1 600.0	
			02	សហគ្រាសខេត្តនានា	3 050.0									
		02		ការបង់ប្រាក់រំលស់ឡើងវិញ	3 900.0									
			01	សហគ្រាសមជ្ឈិម	3 700.0									
			02	សហគ្រាសខេត្តនានា	200.0									
		03		ចំនួនលើសនៃទុនចល័ត										
		04		សោហ៊ុយនៃការខិតខំការរបស់សហគ្រាសសាធារណៈ										
		05		ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ										
		06		ផលទុនរបស់អាកាសចរណ៍ស៊ីវិល	12 000.0						12 000.0			
		07		ផលទុននៃសកម្មភាពពាណិជ្ជ										

	ក្រសួងមហាផ្ទៃ ទូទៅ	ក្រសួងពត៌មាន	ក្រសួងសាធារណៈការ និង ដឹកជញ្ជូន	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	ក្រសួងយុត្តិធម៌ តុលាការកំពូល	ក្រសួងយុត្តិធម៌ សាលាឧទ្ធរណ៍	ក្រសួងអប់រំ យុវជន និង កីឡា	ក្រសួងពាណិជ្ជកម្ម	ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល	ក្រសួងផែនការ	ក្រសួងសុខាភិបាល	ក្រសួងទេសចរណ៍	សណីយ និង ទូរគមនាគមន៍	វប្បធម៌ និង វិចិត្រសិល្បៈ	ក្រសួងបរិស្ថាន
				18 580.0					630.0						
									605.0						
									25.0						
				18 580.0											
			685.0												
			165.0												
			500.0												
			20.0												
			150.0					245.0		105.0		90.0	30.0		
			25.0												
				1000.0					50.0						
		405.0	690.0		60.0	10.0	220.0	840.0	10.0		100.0	60.0	80 000.0	100.0	
													80 000.0		
		405.0													
			370.0		60.0	10.0		740.0	10.0		100.0	60.0		100.0	
											100.0				
											100.0				
10														100.0	
								450.0	10.0						
								290.0				60.0			
			50.0												

[illegible]	[illegible] ទូទៅ	ក្រសួង ពត៌មាន	សាធារណការ និង ដឹកជញ្ជូន	កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	យុត្តិធម៌ តុលាការកំពូល	យុត្តិធម៌ សាលាឧទ្ធរណ៍	អប់រំ យុវជន និង កីឡា	ពាណិជ្ជកម្ម	ឧស្សាហកម្មរ៉ែ និង ថាមពល	ក្រសួង ផែនការ	ក្រសួង សុខាភិបាល	ក្រសួង ទេសចរណ៍	សណីយ និង ទូរគមនាគមន៍	វប្បធម៌ និង វិចិត្រសិល្បៈ	ក្រសួង បរិស្ថាន
				18 580.0					630.0						
									605.0						
									25.0						
				18 580.0											
			685.0												
			165.0												
			500.0												
			20.0												
[illegible]			150.0					245.0		105.0		90.0	30.0		
			25.0												
				1000.0					50.0						
[illegible]		405.0	690.0		60.0	10.0	220.0	840.0	10.0		100.0	60.0	80 000.0	100.0	
													80 000.0		
		405.0													
			370.0		60.0	10.0		740.0	10.0		100.0	60.0		100.0	
											100.0				
											100.0				
400.0														100.0	
								450.0	10.0						
								290.0				60.0			
			50.0												

ការគ្រប់គ្រង ឆ្នាំ ១៩៩៦
ចំណូលថវិកាចរន្តរបស់រដ្ឋ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ការរាយមុខចំណូល	សរុបរួមចំណូលថវិកា	ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គយនិងរដ្ឋាករ	ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពន្ធដារ	ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ព្រះបរមរាជវាំង	ទីស្តីការគណៈរដ្ឋមន្ត្រីផ្ទាល់	អគ្គលេខាធិការដ្ឋានអាកាសចរស៊ីវិល	ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	ក្រសួងការពារជាតិ	ក្រសួងមហាផ្ទៃសន្តិសុខសាធារណៈ
	[illegible]			កំរៃយកមុនក្នុងសម្បទានទ្រព្យសម្បត្តិរដ្ឋ	19 210.0									
		01		សម្បទានពីរប្រេងកាត	605.0									
		02		សម្បទានពីរែ	25.0									
		10		សម្បទានផ្សេងៗទៀត	18 580.0									
	05			ពន្ធលើការកាន់កាប់កម្មសិទ្ធិសាធារណៈ	6 880.0			6 195.0						
		01		ផលនៃការជួលកន្លែងលក់ដូរក្នុងទីផ្សារ	4 000.0			4 000.0						
		02		ពន្ធចំណតរថយន្ត	600.0			435.0						
		03		ពន្ធកំពង់ចម្លង	1 880.0			1 380.0						
		04		ពន្ធកន្លែងលក់ដោយការដេញថ្លៃ	400.0			380.0						
	06			ការជួលអចលនវត្ថុ	3 000.0			405.0				1 800.0		65.0
	07			ផលពីការលក់ផ្ទៃកគយ	500.0	500.0								
	08			ផលបានមកពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈដើរពាសវាលពាសកាលគ្មានម្ចាស់ និងទំនិញបោះបង់ចោល										
	09			ផលពីការលក់ចលនវត្ថុរបស់រដ្ឋ	100.0			75.0						
	20			ផលផ្សេងៗទៀតពីទ្រព្យសម្បត្តិរដ្ឋ	1 500.0			450.0						
21				ជំពូក៦១ : ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ	98 460.0	850.0	20.0	3445.0	50.0	700.0		1.600.0		9 300.0
	01			ផលទូរប្រៃសណីយ៍ និង ទូរគមនាគមន៍	80 000.0									
	02			ផលទូរទ វិទ្យុ ទូរទស្សន៍ ការផ្សាយ	405.0									
	03			ចំណូលនៃសេវាកម្មសាធារណៈ	13 980.0	850.0	20.0	10.0	50.0	700.0		1600.0		9 300.0
		01		កំរៃនៃការថែទាំ	100.0									
		02		ការលក់សំភារៈសិក្សា										
		03		អាករនៃស្ពានចម្លង	10 900.0							1 600.0		9 300.0
		04		ផលទុននៃសកម្មភាពវប្បធម៌	150.0				50.0					

ការគ្រប់គ្រង ឆ្នាំ ១៩៩៦
ចំណូលថវិកាចរន្តរបស់រដ្ឋ

ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៦
ទំព័រ ៦/៦ ឯកតា លានរៀល

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង វាក្យខណ្ឌ

ជំពូក	ប្រការ	កថាខណ្ឌ	វាក្យខណ្ឌ	ការរាយមុខចំណូល	សរុបរួមចំណូលថវិកា	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គយនិងរដ្ឋាករ	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពន្ធដារ	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ព្រះបរមរាជវាំង	ទីស្តីការគណៈរដ្ឋមន្ត្រីផ្ទាល់	រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	ក្រសួងការពារជាតិ	ក្រសួងមហាផ្ទៃ សន្តិសុខសាធារណៈ	[illegible]
		04		បារាំង											
		05		អូស្ត្រាលី											
		06		ស៊ុយអែដ											
		07		ចក្រភពអង់គ្លេស											
		08		អាល្លឺម៉ង់											
		30		ផ្សេងៗទៀត											
	04			អំណោយដោយឡែកសំរាប់រំលស់បំណុល											
32				ជំពូក៣២: ប្រភពទ្រព្យសម្បត្តិបានមកពីការខ្ចីបុល	272 250.0			272 250.0							
	01			ប្រភពទុនខ្ចីផ្ទៃក្នុង	12.000.0			12.000.0							
		01		ប្រភពទុនខ្ចីផ្ទៃក្នុងបានមកពីប្រព័ន្ធ	12.000.0			12.000.0							
				....											
		02		ប្រភពទុនខ្ចីផ្ទៃក្នុងផ្សេងៗទៀត											
				....											
	02			ប្រភពទុនខ្ចីពីបរទេស	260.250.0			260.250.0							
		01		ប្រភពទុនខ្ចីពីបរទេសបានមកពីអង្គការអន្តរជាតិនានា	260.250.0			260.250.0							
			01	ធនាគារពិភពលោក	113 750.0			113.750.0							
				មូលនិធិបដិភាគ	62.500.0			62.500.0							
				ឥណទានខ្ចី	51.250.0			51 250.0							
			02	ធនាគារអាស៊ីសំរាប់អភិវឌ្ឍន៍	146 500.0			146.500.0							
				មូលនិធិបដិភាគ	37 500 0			37 500 0							
				ឥណទានខ្ចី	109 00 0			109.00.0							

ល្បេ

ក្រសួង មហាផ្ទៃ សន្តិសុខ សាធ. [illegible]	ក្រសួង មហាផ្ទៃ រដ្ឋបាល ទូទៅ	ក្រសួង ព័ត៌មាន	ក្រសួង សាធារណការ និង ដឹកជញ្ជូន	ក្រសួង កសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ	ក្រសួង យុត្តិធម៌ តុលាការកំពូល	ក្រសួង យុត្តិធម៌ សាលាឧទ្ធរណ៍	ក្រសួង អប់រំ យុវជន និង កីឡា	ក្រសួង ពាណិជ្ជកម្ម	ក្រសួង ឧស្សាហកម្មរ៉ែ និង ថាមពល	ក្រសួង ផែនការ	ក្រសួង សុខាភិបាល	ក្រសួង ទេសចរណ៍	ក្រសួង ប្រៃសណីយ៍ និង ទូរគមនាគមន៍	ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ	ក្រសួង បរិស្ថាន

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២២ អនក្រ.គត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ឆ្នាំ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត. ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិ ចំពោះក្រុមហ៊ុន SATAKE CORPORATION « ជប៉ុន » ដែលបានធ្វើអំណោយរោងម៉ាស៊ីនកិនស្រូវ ០១ គ្រឿងមានតំលៃប្រមាណ ៧ សែនដុល្លារអាមេរិក ជូនដល់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២៣ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ឆ្នាំ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ : តែងតាំងលោក **មុត ខៀវ** ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

២ - សេចក្តីសម្រេច

រាជធានីភ្នំពេញ ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

សេចក្តីសម្រេច លេខ ០៣ សសរ

ស្តីពីការបង្កើតក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះរាជកុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ឆ្នាំ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

សំរេច

ប្រការ ១ : បង្កើតក្រុមការងារជាតិមួយឈ្មោះថា « ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា » ដើម្បីអភិវឌ្ឍន៍ វិស័យឧត្តមសិក្សា ។

ប្រការ ២ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា មានសមាសភាពដូចខាងក្រោម ÷

+ ឯកឧត្តម **គាត ឈន់**	ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍	ប្រធាន
+ឯកឧត្តម **តុល ឡោះ**	រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា	អនុប្រធាន
+ឯកឧត្តម **ជា ចាន់តូ**	រដ្ឋមន្ត្រីក្រសួងផែនការ	សមាជិក
+ឯកឧត្តម **តាវ សេងហួរ**	រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ	សមាជិក

+ឯកឧត្តម ឈា ថាំង រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក

+ឯកឧត្តម ពូ សុធីរៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សមាជិក

+ឯកឧត្តម នុត ណារ៉ាង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

+លោក អ៊ុច ថុង តំណាងគ្រឹះស្ថានឧត្តមសិក្សា សមាជិក

+លោក តឹក ចុំយ តំណាងនយោជកឯកជនជាតិ ទីប្រឹក្សា

+លោក អេហ្គា ជូ តំណាងនយោជកឯកជនបរទេស ទីប្រឹក្សា

+លោក គ្រឹស ម៉ាឡុយ តំណាងនយោជកចំរុះរដ្ឋ–ឯកជន ទីប្រឹក្សា

ប្រការ ៣ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា មានសិទ្ធិបង្កើតក្រុមការងារជាតិ ដែលមានសមាសភាព ពីស្ថាប័នឧត្តមសិក្សា អ្នកឯកទេស អង្គការផ្តល់ជំនួយ ដើម្បីអនុវត្តការងារ ។

ប្រការ ៤ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា មានភារកិច្ចដូចតទៅ ÷

- ជំនួយការអោយរាជរដ្ឋាភិបាល លើការអភិវឌ្ឍន៍វិស័យឧត្តមសិក្សាក្នុងផែនការសកម្មភាពជាតិ ដើម្បីអោយការវិនិយោគក្នុងវិស័យនេះមានការរីកចំរើន ទាន់សភាពការណ៍ និងមានប្រសិទ្ធភាព ។
- ដឹកនាំ ត្រួតពិនិត្យ កែលំអផែនការសកម្មភាពជាតិ ដែលរៀបចំឡើងដោយក្រុមការងារជាតិ ដើម្បីដាក់ជូនសុំសេចក្តីសំរេចពីរាជរដ្ឋាភិបាល ។

ប្រការ ៥ : សមាជិកនៃក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សា ត្រូវចូលរួមប្រជុំ និងធ្វើការងារតាម សេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន ។

ប្រការ ៦ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សាមានសិទ្ធិប្រើប្រាស់ត្រាក្រុម ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសំរួលការងារ ។

ប្រការ ៧ : ក្រុមដឹកនាំការងារជាតិសំរាប់ឧត្តមសិក្សាមានអាណត្តិ ១៨ ខែ ។

ប្រការ ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទីតិសម្បទា និងអភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បណ្តាស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស ០១០ ប្រក.សហវ

ស្តីពីការបង្កើតគណៈកម្មការដោះស្រាយវិវាទ

លើការតវ៉ាអំពីអធិការកិច្ចនិងញូមុខពេលផ្ទុក

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកាឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រុមហ៊ុន (SGS) ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពីការធ្វើអធិការកិច្ចមុនពេលផ្ទុក ។
- បានឃើញប្រកាសលេខ ៣២១ ប្រកសហវ.គរ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការ អនុវត្តសេវាអធិការកិច្ចមុនពេលផ្ទុក សំរាប់នាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញលិខិតស្តីពីការចាត់មន្ត្រីចូលរួមក្នុងគណៈកម្មការដោះស្រាយវិវាទ លើការតវ៉ាអំពីអធិការកិច្ចទំនិញមុនពេលផ្ទុក លេខ ១០០១.៩៥ កអក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លេខ២៣៩១ ពណមទ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ របស់ក្រសួង ពាណិជ្ជកម្ម លេខ ៦ សភពភព ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងលេខ ១៦៦៦.៩៥ គរ ចុះ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ទីចាត់ការគយ និងរដ្ឋាករ ។
- យោងតាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការដោះស្រាយវិវាទលើការតវ៉ាអំពីអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) មួយដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២-ឯកឧត្តម **ខាំ ម៉េងឈាង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៣-លោក **សារ៉ាក់ ខាន់** អគ្គនាយកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤-លោក **ឆេង សារឿន** នាយកកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក

៥-លោក **អ៊ុត ចរ៉ាឧត្ដម** ទីប្រឹក្សាប្រចាំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៦-លោក **លឹម សុគាត** ទីប្រឹក្សា នៃសភាពាណិជ្ជកម្ម សមាជិក

៧-លោក **សឿង ឈុនទ្រី** នាយករងទីចាត់ការគយ និងរដ្ឋាករ សមាជិក

៨-លោក **ខាំ អៀងម៉េង** មន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខាកត់ត្រា

ប្រការ ២ : គណៈកម្មការដោះស្រាយវិវាទលើការតវ៉ាអំពីអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) មាន ភារកិច្ចដោះស្រាយរាល់វិវាទទាំងឡាយដែលកើតមានឡើង រវាង អ្នកនាំចូល និងក្រុមហ៊ុនអធិការកិច្ច (SGS) ដោយត្រូវសំរេចលើការវិវាទ នេះក្នុង រយៈពេល ០១ ខែ យ៉ាងយូរ ក្រោយពីបាន ទទួលសំណុំលិខិតតវ៉ា របស់អ្នកនាំចូល ។

ប្រការ ៣ : ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

គាត ឈន់

* * *

២ - **ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស ០៥២ ពណ.ចល.ប្រក

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកាឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសំរួលសមាសភាពរាជ រដ្ឋាភិបាលកម្ពុជា ។
- ពិនិត្យលើការងាររបស់ចាំបាច់របស់ក្រសួង

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចាត់តាំងពិព័រណ៍ពាណិជ្ជកម្មមួយរបស់ក្រសួង ដើម្បីរៀបចំតុបតែង ផ្សព្វផ្សាយតាំង និងលក់ទំនិញដែលរួមមានសមាសភាព

ដូចខាងក្រោម ÷

១–ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រី ជាប្រធាន

២–ឯកឧត្តម **លី ឡាយស្រេង** រដ្ឋលេខាធិការ ជាអនុប្រធាន

៣–ឯកឧត្តម **នុច សំ** អនុរដ្ឋលេខាធិការ ជាអនុប្រធាន

៤–ឯកឧត្តម **គីម សាន្ត** អនុរដ្ឋលេខាធិការ ជាអនុប្រធាន

៥–លោក **កែវ សុខណៃ** ប្រធានមន្ទីរ ជាសមាជិក

៦–លោក **គីម ស៊ីថន** ប្រធាននាយកដ្ឋានបុគ្គលិក ជាសមាជិក

៧–លោក **ទិវ ជាង** ប្រធានក្រុមហ៊ុនសៀង ជាសមាជិក

៨–លោក **គឹម ឡឿន** ប្រធាននាយកដ្ឋានគណនេយ្យ ជាសមាជិក

៩–លោក **លឹម សំអាត** ប្រធានក្រុមហ៊ុនកាំប៉ិចស៊ីម ជាសមាជិក

១០–លោក **ម៉ៅ ថុរ៉ា** ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ជាសមាជិក

១១–លោក **ឆេង សារឿន** នាយកទីចាត់ការកាំកុងត្រូល ជាសមាជិក

១២–លោក **សុខ សាផល** ប្រធានក្រុមហ៊ុនកាំត្រេង ជាសមាជិក

១៣–លោក **គោះ យ៉ាន** អនុប្រធាននាយកដ្ឋានផែនការ ជាសមាជិក

១៤–លោក **កែ ផៃ** អនុប្រធានក្រុមហ៊ុនប្រមូលទិញ ជាសមាជិក

១៥–លោក **ទេស អែតដា** អនុប្រធានក្រុមហ៊ុនសំភារៈបរិក្ខា ជាសមាជិក

១៦–លោក **ស៊ូ សាញ់** អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យ ជាសមាជិក

១៧–លោក **សួស ចណ្ណា** អនុប្រធាននាយកដ្ឋានបុគ្គលិក ជាសមាជិក

១៨–លោក **ឈួន ដារ៉ា** អនុប្រធានក្រុមហ៊ុនស្ថាបនា ជាសមាជិក

១៩–លោក **លីច មិនចំនួ** ទីប្រឹក្សា ជាសមាជិក

២០–លោក **លឹម សុគន្ធា** ទីប្រឹក្សា ជាសមាជិក

២១–លោក **ហ៊ុល ឌុល** ទីប្រឹក្សា ជាសមាជិក

២២–លោក **យឹម សុខុម** ជាសមាជិក

២៣–លោក **ឡាក់ ចំរើន** ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកណ្តាល ជាសមាជិក

ប្រការ ២ : ចាត់តាំងអនុគណៈកម្មការចំនួន ០៥ ដើម្បីជំនួយការដល់គណៈកម្មការពិពរ័ណ៍ពាណិជ្ជកម្មរួមមាន សមាសភាពដូចខាងក្រោម ៖

I - <u>អនុគណៈកម្មការរៀបចំតុបតែង</u> ៖

១–លោក **អ៊ុយ សុខារ៉ាត្ន** អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ជាប្រធាន

២–លោក **ឈួន ដារ៉ា** អនុប្រធានក្រុមហ៊ុនស្តាបនា ជាអនុប្រធាន

៣–លោក **សាយ សារ៉េន** អនុប្រធាននាយកដ្ឋានបុគ្គលិក ជាសមាជិក

៤–លោក **ស៊ុយ ឡឿន** អនុប្រធានក្រុមហ៊ុនស្បៀងកម្ពុជា ជាសមាជិក

៥–លោក **សរ សំណាង** ប្រធានការិយាល័យគណនេយ្យកាំប៉ុចស៊ីម ជាសមាជិក

៦–លោក **ឌិន ទ៉ាន់នី** អនុប្រធានការិយាល័យចាត់តាំងនាយកដ្ឋានបុគ្គលិក ជាសមាជិក

អនុគណៈកម្មការនេះមានភារកិច្ច

–ជ្រើសរើសទីតាំងរៀបចំពិពរ័ណ៍

–រៀបចំ តុបតែង ទីកន្លែងនីមួយៗសំរាប់តាំងទំនិញ

II - <u>អនុគណៈកម្មការរដ្ឋបាល និង ហិរញ្ញវត្ថុ</u> :

១–លោក **គីម ឆឿន** ប្រធាននាយកដ្ឋានគណនេយ្យ ជាប្រធាន

២–លោក **ខៀវ សុគិន** អនុប្រធាននាយកដ្ឋានគណនេយ្យ ជាអនុប្រធាន

៣–លោក គោះ យាន អនុប្រធាននាយកដ្ឋានផែនការ ជាសមាជិក

៤–លោក អ៊ុំ សំផន អនុប្រធានមន្ទីរ ជាសមាជិក

៥–លោក ទិម សំអុល អនុប្រធានការិយាល័យបៀវត្ស ជាសមាជិក

៦–លោក មុំ ចំនួនតារា បុគ្គលិកនាយកដ្ឋានគណនេយ្យ ជាសមាជិក

៧–លោក ចិន សារម៉េត បុគ្គលិកនាយកដ្ឋានគណនេយ្យ ជាសមាជិក

អនុគណៈកម្មការនេះមានភារកិច្ច ទទួលលិខិតស្នាមតិតតួរចំណូល ចំណាយក្នុងការងាររៀបចំពិព័រណ៍ពាណិជ្ជកម្មរបស់ក្រសួង ។

III - អនុគណៈកម្មការផ្សព្វផ្សាយទំនាក់ទំនងសាធារណៈ ៖

១–លោក ម៉ៅ ថូរ៉ា ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ជាប្រធាន

២–លោក សម សម្បត្តិ អនុប្រធានក្រុមហ៊ុនកាំប៉ិចស៊ីម ជាអនុប្រធាន

៣–លោក រស់ នីមសារុន អនុប្រធានក្រុមហ៊ុនប្រេងឥន្ធនៈកម្ពុជា ជាសមាជិក

៤–លោក ចន្ទ្រ ចន្ទតារា អនុប្រធានការិយាល័យរដ្ឋបាល ជាសមាជិក

៥–លោក សំ សេរីវុឌ្ឍ មន្ត្រីនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ជាសមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចរកប្រភពទំនិញសំរាប់តាំងពិព័រណ៍ និង ធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មដល់អតិថិជន និង ទំនាក់ទំនងជាមួយបណ្តាក្រុមហ៊ុនឯកជន ។

IV - អនុគណៈកម្មការសិល្បៈ

១–លោក ឆេង អ៊ែនដារ៉ា អនុប្រធានក្រុមហ៊ុនសំភារៈបរិក្ខារ ជាប្រធាន

២–លោក ឆេង សារឿន នាយកទីចាត់ការកាំកុងត្រូល ជាអនុប្រធាន

៣–លោកស្រី ឡៅ៊ង សារ៉ាត់ អនុប្រធានមន្ទីរ ជាសមាជិក

៤–លោក រស់ ឆេរិទ្ធ អនុប្រធានការិយាល័យបៀវត្ស ជាសមាជិក

៥–លោក ហ៊ឹម ម៉ាន អនុប្រធានការិយាល័យផែនការ ជាសមាជិក

អនុគណៈកម្មការសន្តិសុខ–សណ្តាប់ធ្នាប់

១–លោក ស៊ុំ សាឡន់ អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យ ជាប្រធាន

២–លោក សួស ចណ្ណា អនុប្រធាននាយកដ្ឋានបុគ្គលិក ជាអនុប្រធាន

៣–លោក យ៉ឺន សារុន ប្រធានការិយាល័យបុគ្គលិក ជាសមាជិក

៤–លោក យ៉ឺន សុចណ្ណ អនុប្រធានការិយាល័យការពារ ជាសមាជិក

៥–លោក ឃឹម សារិទ្ធ អនុប្រធានការិយាល័យបុគ្គលិក ជាសមាជិក

៦–លោក ហោង សេង សន្តិសុខ ជាសមាជិក

អនុគណៈកម្មការនេះ មានភារកិច្ចរៀបចំសណ្តាប់ធ្នាប់ ការពារ យាមកាមទីកន្លែងតាំងពិពរណ៍ ។

ប្រការ ៣ : សមាជិកគណៈកម្មការ និងអនុគណៈកម្មការត្រូវចូលរួមប្រជុំពិភាក្សាតាមការអញ្ជើញរបស់ ប្រធាន ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក និងឯកឧត្តម អស់លោក ដែលមានឈ្មោះខាងលើត្រូវទទួលអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

លី ឡាយស្រេង

* * *

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទិ ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស លេខ ៨១ ឧក.ប្រក

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា
- បានឃើញលិខិតលេខ ២៩៥ / ៩៤ គ.វ.ក. ចុះថ្ងៃទី ១៦.៩.៩៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៤៧២ បជ ចុះថ្ងៃទី ២១.១២.៩៥ របសសាលាក្រុងភ្នំពេញ ស្តីពីការឯកភាព លើទីតាំង រោងចក្រផលិតស្រោមដៃ ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ប៉ូតាម៉ុង ខេមបូឌា ចុះថ្ងៃទី ១៧.១២.៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ប៉ូតាម៉ុង ខេមបូឌា (POTAMON CAMBODIA Co LTD) តំណាងដោយលោក KENNETH SUEN ជនជាតិខ្មែរ សញ្ជាតិអាមេរិកាំង អាស័យដ្ឋាន ផ្ទះលេខ ៥៤ ផ្លូវលេខ ១៤៣ សង្កាត់វាលវង់ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ កាន់លិខិតឆ្លងដែនលេខ ០៣៣ ៦៦ ២២២១ ចុះថ្ងៃទី ២៣.៦.៩០ បង្កើត «រោងចក្រផលិតស្រោមដៃសំរាប់នាំចេញ »ដែលមានឈ្មោះ «រោងចក្រផលិតស្រោមដៃ ប៉ូតាម៉ុង » មានទីតាំងស្ថិតនៅផ្ទះលេខ ៥៤ ផ្លូវលេខ ១៤៣ សង្កាត់វាលវង់ ខ័ណ្ឌ ៧ មករា រាជធានី ភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រផលិតស្រោមដៃ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៣ : សាមីក្រុមហ៊ុនត្រូវធ្វើរបាយការណ៍ជូនក្រសួង ជារៀងរាល់ខែ ពីស្ថានភាពផលិតកម្ម–អាជីវកម្មរបស់រោងចក្រ ។

ប្រការ ៤ : ក្នុងកិច្ចដំណើរការរោងចក្រ សាមីក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារ បរិស្ថាន និងធានាគុណភាពផលិតព្រមទាំងត្រូវគោរពច្បាប់ និងបទបញ្ញត្តិទាំងឡាយដែល មានជាធរមាន ។

ប្រការ ៥ : រោងចក្រនេះ ត្រូវបានអនុញ្ញាតអោយផលិតស្រោមដៃ ស្របតាមគំរូដែលតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តិល្មើស នឹងប្រការណាមួយ ដែលបានចែងខាងលើប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៧ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋាន នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ដែលមានភារកិច្ច និងលោក KENNETH SUEN ត្រូវអនុវត្តតាមប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ ៨ : ប្រកាសនេះ មានអនុភាពតតិយុត្តិចាប់ថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៤ - ឧត្ដមការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស លេខ ០៣៨ /៩៦ ព.ម.ប្រក

អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅឈ្មោះ POCKET GUIDE

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១

- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា នៃ ព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/៨០៩៥ / ០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។
- បានឃើញសំណើសុំបោះពុម្ពផ្សាយសៀវភៅឈ្មោះ POCKET GUIDE របស់លោក NIELS STORM MERTENS COLOV ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅឈ្មោះ CAMBODIA POCKET GUIDE ដោយមានលោក NIELS STORM MARTENS COLOV ជាម្ចាស់ហាងការផ្សាយ ។ ទីស្នាក់ការលេខ ១៦ ផ្លូវ៦៣ ខណ្ឌដូនពេញ រាជធានី ភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណប័ណ្ណ នៃសារពត៌មានរបស់ខ្លួនត្រូវជូនដំណើងជាមុនមកក្រសួងពត៌មាន ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត ឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តអោយសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងយកសៀវភៅនេះចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាង លើ សាមីខ្លួនត្រូវ ទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : លោក NIELS STORM MARTENS - COLOV ចាងហ្វាងការផ្សាយ និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងមានត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

៥ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស លេខ : ១១៣ អយក.ប្រក

ស្តីពីផ្លាច់សាលាឧបសម្ព័ន្ធគុមិទ្ធស្សី

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤

- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រចៈ ចុះថ្ងៃទី ២០-១១-១៩៨៦ ស្ដីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ តុលា ១៩៨៦ ស្ដីពីការកំនត់បទដ្ឋានប្រើ ប្រាស់ក្របខ័ណ្ឌ សំរាប់អង្គភាពអប់រំនានា
- បានពិនិត្យលិខិតស្នើសុំ របស់មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ លេខ ៥៩៨ លស. ចទម. ចុះថ្ងៃទី ១៥ ធ្នូ ១៩៩៥
- តាមយោបល់ឯកភាព របស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ ផ្ដាច់សាលាភូមិឫស្សីឧបសម្ព័ន្ធ សាលាបឋមសិក្សា ស្ទឹងមានជ័យ មកជា សាលាបឋមសិក្សាភូមិឫស្សីពេញលក្ខណៈ ចាប់ពី ឆ្នាំ ១៩៩៦ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សាភូមិឫស្សី ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក និងនាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋាន ផែនការហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ ការិយាល័យអប់រំ យុវជន និង កីឡា ខណ្ឌមានជ័យ នាយកសាលាបឋមសិក្សា

ស្ទឹងមានជ័យ នាយកសាលាបឋមសិក្សាភូមិឫស្សី មានភារៈកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
គា សាហាន

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស លេខ : ១១៤ អយក.ប្រក

ស្តីពីប្តូរឈ្មោះសាលាបឋមសិក្សា វត្តធ្វូច

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល
– បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
– បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
– បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ២៥ តុលា ១៩៨៦ ស្តីពីការកំនត់បទដ្ឋានប្រើ ប្រាស់ក្របខ័ណ្ឌ សំរាប់អង្គភាពអប់រំនានា ,

- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និងកីឡា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង លេខ ៩០-៩៥ ចុះថ្ងៃទី ១៤ -១០ - ១៩៩៥
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយការិយាល័យអប់រំ យុវជន និង កីឡា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ប្តូរ ឈ្មោះសាលាបឋមសិក្សាវត្តថ្កូវ នៅភូមិត្បែង ឃុំថ្កូវ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង មកជា « សាលាបឋមសិក្សា **ស ខេង** វត្តថ្កូវ » ចាប់ពីឆ្នាំសិក្សា ១៩៩៥ - ១៩៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : មន្ទីរក្រសួងអប់រំ យុវជន និង កីឡា នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការ ហិរញ្ញកិច្ច នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តព្រៃវែង ការិយាល័យអប់រំ យុវជន និង កីឡា ស្រុកកំពង់ត្របែក សាលាបឋមសិក្សា **ស ខេង** វត្តថ្កូវមានភារៈ កិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាខន

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស លេខ : ១១៥ អយក. ប្រក

ស្តីពីការបើកវិទ្យាល័យ ស៊ីមខ្លុល ជាឧបសម្ព័ន្ធរបស់វិទ្យាល័យ

ព្រែកអញ្ចាញ ក្នុងស្រុកមុខកំពូល ខេត្តកណ្តាល

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះ ទូទៅ ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពី ការបើកសាលា មធ្យមសិក្សាកំរិត១ - កំរិត២
- យោងសំណើរបស់ព្រះសង្ឃ និងសមាគមមាតាបិតាសិស្សអនុវិទ្យាល័យសិរីមង្គល ដោយ មានការឯកភាពពីប្រធានមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្ត ខេត្តកណ្តាល
- តាមសំណើរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកណ្តាល បើកវិទ្យាល័យសិរីមង្គល ជា ឧបសម្ព័ន្ធរបស់វិទ្យាល័យព្រែកអញ្ចាញ ក្នុងស្រុកមុខកំពូល ខេត្តកណ្តាល ចាប់ពីឆ្នាំសិក្សា ១៩៩៥ - ១៩៩៦ តទៅ ។

ប្រការ ២ : វិទ្យាល័យសិរីមង្គល ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់វិទ្យាល័យ ព្រែកអញ្ចាញ ។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋាន បុគ្គលិក ប្រធាននាយកផែនការ ហិរញ្ញកិច្ច នៃក្រសួងអប់រំ

យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា និង នាយកវិទ្យាល័យ ព្រែកអញ្ចាញមាន ភារៈកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស លេខ : ១១៦ អយក. ប្រក

ស្តីពីការរៀបចំប្រព្រឹត្តិទៅនៃការប្រលងសញ្ញាប័ត្រ

មធ្យមសិក្សាកំរិត ២

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ២២៣៧ សជណ. អរ ចុះថ្ងៃទី ១៩-១១-១៩៩០ ស្តីពីការប្តូរឈ្មោះសាលារៀនចំណេះទូទៅ
- បានឃើញប្រកាសក្រសួងលេខ ២៣២៩ ចុះថ្ងៃទី ១៧.៥.១៩៨០ ស្តីពីការប្រលងសញ្ញាប័ត្រកំរិតសិក្សាទី ៣

– យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និង កីឡា

សំរេច

ប្រការ ១ : មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ លើកទី១ និង លើកទី២ ត្រូវកំណត់ ដោយក្រសួងអប់រំ យុវជន និង កីឡា រៀងរាល់ឆ្នាំសិក្សា ។

ប្រការ ២ : ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត -ក្រុង និង នាយកគ្រឹះស្ថានសិក្សា ដែលគ្រឹះ ស្ថានត្រូវបានកំនត់ជាមណ្ឌលប្រលងមានភារៈ រៀបចំបន្ទប់ប្រលង សៀវភៅ រូបថតបេក្ខជន បញ្ជីផ្សេង ។ និងសំភារៈ ចាំបាច់សំរាប់ការប្រព្រឹត្តិទៅនៃការប្រលង អោយហើយស្រេច មុន បើកសម័យប្រលង ។

– ចំពោះសាលាក្រោមឱវាទផ្ទាល់ នៃក្រសួងអប់រំ យុវជន និង កីឡា នាយកគ្រឹះស្ថានសិក្សា ក៏ត្រូវអនុវត្តដូចមណ្ឌលនានាដែរ តាមការណែនាំរបស់នាយកដ្ឋានចំនេះទូទៅ និង មធ្យម សិក្សា ។

ប្រការ ៣ : នឹងអាចចុះឈ្មោះប្រលងលើកទី ១ បាន បេក្ខជនទាំងឡាយណាជាសិស្សថ្នាក់ទី ១១ នៃ វិទ្យាល័យសាធារណៈ និងឯកជនដែលបានរៀបចំកម្មវិធីសិក្សាថ្នាក់ទី១១ ។ ពាក្យសុំចុះ ឈ្មោះប្រលងមានបិទតែមប្រ៍ ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា តាមឋានា នុក្រម ។

ប្រការ ៤ : និងអាចអនុញ្ញាតអោយចូលរួមប្រលងលើកទី ២ បាន ៖

. បេក្ខជនដែលប្រលងធ្លាក់លើកទី១ និងបានពិន្ទុសរុបនៃការប្រលង លើកទី១ ចាប់ ពី៣/៤ នៃពិន្ទុ២៥០ (គឺចាប់ពីពិន្ទុ១៨០)ឡើងទៅ ។

. បេក្ខជនដែលបានដាក់ពាក្យសុំប្រលងលើកទី១ តែអាក់ខានពុំបានចូលរួមប្រលង ឬបានចូលរួមប្រលងពុំបានគ្រប់មុខវិជ្ជា ដោយមូលហេតុមាន ជំងឺឬគ្រោះថ្នាក់ផ្សេងៗជាក់ស្តែង ហើយមានពាក្យសុំច្បាប់ត្រឹមត្រូវ ដោយ មានការបញ្ជាក់ពីឪពុកម្តាយ ឬ អាណាព្យាបាល ស្នើសុំទៅរដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា តាមរយៈប្រធានមណ្ឌល ដែលសាមុីខ្លួនត្រូវ ប្រលង ។

ប្រការ ៥ : អាចសុំចុះឈ្មោះប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ជាបេក្ខជនសេរីយរិន បាន អតីតបេក្ខជនដែលបាន ប្រលងធ្លាក់ សញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ។

ប្រការ ៦ : បេក្ខជន ត្រូវភ្ជាប់នឹងពាក្យសុំប្រលងរបស់ខ្លួននូវ

- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាកំរិត១ ១ សន្លឹក
- សលាកប័ត្រឯកត្តជនទំហំ ១៥ ស.ម គុណនឹង ២១ ស.ម មានបិទរូបថតថ្មី ថតចំពីមុខទំហំ ៤ ស.ម × ៦ ស.ម ចំនួន ៤ សន្លឹក
- បង្កាន់ដៃបង់សិទ្ធិប្រលង ១ ច្បាប់
- រូបថត ថតថ្មី ថតចំពីមុខ ទំហំ ៤ ស.ម គុណ ៦ ស.ម «រូបដែលបានបិទលើ សលាកប័ត្រឯកត្តជន» ចំនួន ៣ សន្លឹក
- សៀវភៅសិក្ខាគារិក «ចំពោះសិស្សសាលាឯកជន»

ប្រការ ៧ : ពាក្យសុំចុះឈ្មោះប្រលងលើកទី ១ និងលើកទី ២ នឹងត្រូវប្រមូលផ្តុំតាមគ្រឹះស្ថានសិក្សាដែល ខ្លួនសិក្សា ។ នាយកគ្រឹះស្ថានសិក្សា ត្រូវប្រមូលសំណុំលិខិតរបស់បេក្ខជន បញ្ជូនទៅមន្ទីរ អប់រំ យុវជន និង កីឡា ខេត្ត - ក្រុង ដើម្បីធ្វើការបែងចែកឈ្មោះបេក្ខជនតាមលំដាប់អក្សរទៅតាមបន្ទប់ប្រលង។

ប្រការ ៨ : បេក្ខជនដែលបានប្រកាសថាត្រូវបានប្រឡងលើកទី ២ មិនបាច់ដាក់ពាក្យប្រលងទៀតទេ ។ មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង មានភារៈរៀបចំបែងចែកឈ្មោះបេក្ខជន តាម លំដាប់អក្សរទៅតាមបន្ទប់ប្រលង ។

ប្រការ ៩ : បេក្ខជនសេរីយរិន ត្រូវដាក់ពាក្យសុំប្រលងលើកទី ១ ដោយមានបញ្ជាក់សម័យប្រលង មណ្ឌលប្រលង លេខបន្ទប់ លេខតុ នៃសម័យប្រលងមុន នៅតាមមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត - ក្រុង ដែលសាមីខ្លួនបានសុំប្រលងពីមុន ឬនៅនាយកដ្ឋានចំនេះទូទៅនិងមធ្យមសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ១០ : មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត- ក្រុង ត្រូវធ្វើបញ្ជីរាយនាមបេក្ខជន ផ្ញើទៅក្រសួងអប់រំ យុវជន និង កីឡា «នាយកដ្ឋានចំនេះទូទៅ និងមធ្យមសិក្សា» ដើម្បីពិនិត្យ និង សំរេច លើបេក្ខភាព ។

ប្រការ ១១ : ការក្លែងបន្លំផ្សេងៗ ពីសំណាក់បេក្ខជន ត្រូវទទួលការបញ្ឈប់មិនអនុញ្ញាតអោយប្រលង ចំនួនពីរឆ្នាំ ។

ប្រការ ១២ : មណ្ឌលប្រលងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និង សមាជិកគណៈមេប្រយោគមួយ ចំនួនតាមការចាំបាច់នៃមណ្ឌលប្រលង ។

ប្រការ ១៣ : សមាសភាព និង ចំនួនព្រមទាំងលិខិតឧទ្ទេសនាមគណៈមេប្រយោគត្រូវសំរេចដោយរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ១៤ : ចំនួនអនុរក្ស នៃមណ្ឌលប្រលង ត្រូវគិតតាមចំនួនបន្ទប់ប្រលង គុណនឹង ២,៥ ។

ប្រការ ១៥ : បន្ទប់ប្រលងនីមួយៗត្រូវដាក់បេក្ខជនត្រឹម ២៥ «ម្ភៃប្រាំ» នាក់ ។ បើមានបេក្ខជននៅសល់ពី ០៥ «ប្រាំ» នាក់ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក ។

ប្រការ ១៦ : ប្រធានគណៈមេប្រយោគនៃមណ្ឌលនីមួយ ។ ជាអ្នកទទួលខុសត្រូវរួមក្នុងដំណើរ ការប្រព្រឹត្តិ ទៅនៃការប្រលង ទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេស ចំពោះក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ១៧ : ប្រធានគណៈមេប្រយោគ ត្រូវសហការ ឬធ្វើអន្តរាគមន៍ ដល់អាជ្ញាធរមានសមត្ថកិច្ចនានាក្នុងខេត្ត-ក្រុងនៃមណ្ឌលប្រលង ក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រលង ។

ប្រការ ១៨ : មណ្ឌល ឬ អនុមណ្ឌលប្រលងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខការណ៍ នៃការប្រលងគណៈមេប្រយោគនៃមណ្ឌល ឬអនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មកគណៈមេ ប្រយោគ ទូទាំងប្រទេសដើម្បី នឹងដោះស្រាយ ឬ សុំការសំរេចពីក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ១៩ : ប្រធានគណៈមេប្រយោគត្រូវបែងចែកភារកិច្ចដល់អនុប្រធាន និង សមាជិក គណៈមេ ប្រយោគ អោយទទួលខុសត្រូវតាមមុខងាររៀង ៗ ខ្លួន ។

ប្រការ ២០ : ភារកិច្ចនៃគណៈកម្មការ អនុគណៈកម្មការ និង សមាជិក នៃគណៈមេប្រយោគ នឹង មានចែងក្នុងសេចក្តីណែនាំមួយរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ប្រការ ២១ : ទៅពេលប្រលងបេក្ខជនទាំងឡាយ ត្រូវមកប្រលងអោយទាន់ពេលវេលា កំណត់ ។ ការមក ប្រលងយឺតយ៉ាវ លើសពី ១៥ នាទី មិនអនុញ្ញាតអោយ ចូលប្រលងឡើយ ។ នៅពេលចូលប្រលងបេក្ខជន ត្រូវមានលិខិតសំគាល់ ខ្លួន មានបិទរូបថត និងមានបញ្ជាក់ច្បាស់លាស់ ។ ជនដែលគ្មានលិខិតសំគាល់ ខ្លួន មិនអនុញ្ញាតអោយចូលប្រលងឡើយ ។

ប្រការ ២២ : មិនអនុញ្ញាតអោយមានការប្រលងជំនួសគ្នាឡើយ ។

ប្រការ ២៣ : មិនអនុញ្ញាតអោយបេក្ខជនទាំងឡាយ យកឯកសារនានាជាប់នឹងខ្លួនចូលក្នុង បន្ទប់ប្រលងជាដាច់ ខាត ។

ប្រការ ២៤ : បេក្ខជនទាំងឡាយត្រូវអង្គុយតាមលេខតុ របស់ខ្លួនគ្រប់វិញ្ញាសា ។

ប្រការ ២៥ : បេក្ខជនទាំងឡាយ ត្រូវធ្វើវិញ្ញាសាលើក្រដាសប្រលង ដែលអនុរក្សចែក អោយ ។ បេក្ខជនមិនត្រូវធ្វើសញ្ញាអ្វី លើក្រដាសប្រលងដែលនាំអោយ ស្គាល់ថា ជាសន្លឹកកិច្ចការរបស់សាមីខ្លួន ជាដាច់ខាត ។ សន្លឹកកិច្ចការដែល មានសញ្ញាសំគាល់ត្រូវបានពិន្ទុសូន្យ ។

ប្រការ ២៦ : នៅពេលធ្វើវិញ្ញាសាប្រលងមិនអនុញ្ញាតអោយបេក្ខជនលួចចំលង ឬមាន បំណងលួចចំលងជាដាច់ខាត ។ កំហុសនៃការលួចចំលង ឬបំណងលួច ចំលង នឹងមានចែងក្នុងអត្ថបទមួយ ។

ប្រការ ២៧ វិញ្ញាសា និង ថេរវេលានៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ លើកទី១ និង លើកទី២ ត្រូវកំនត់ដូចតទៅ ÷

១– តែងសេចក្តី រយៈពេល ៣ ម៉ោង

ប្រការ ៣៩ : នឹងត្រូវប្រកាសថាត្រូវបានប្រលងលើកទី២ បេក្ខជនទាំងឡាយណា ដែលមិនបានប្រកាស ថាប្រលងជាប់លើកទី១ហើយបាន ពិន្ទុសរុបចាប់ពី ១៥០ ឡើងទៅដោយមិនគិតពិន្ទុសូន្យ ចំពោះមុខវិជ្ជាណាមួយ ។

ប្រការ ៤០ : បទបញ្ញត្តិស្តីពីការរៀបចំប្រលងសញ្ញាប័ត្រមធ្យមសិក្សាភូមិភាគ២ ពីមុន ៗ ទាំងឡាយណាដែល ផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៤១ : ប្រធានមន្ទីរ និង ប្រធាននាយកដ្ឋានចំណុះខាងលើ និង មត្តេយ្យសិក្សា និង អង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តតាមភារកិច្ចរៀង ៗ ខ្លួន ដើម្បីអោយបានសំរេចនូវប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

៦ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស លេខ : ០៦៨ សុ.ឧបឡ

ស្តីពីការកំណត់តួនាទី ភារកិច្ច របស់ភ្នាក់ងារ

ត្រួតពិនិត្យឱសថនៅតាមច្រកព្រំដែន

* * *

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ០៥ តុលា ១៩៩.. ស្តីពីការរំសាយនិងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែននិងផ្លូវគមនាគមន៍នៅ ទូទាំងព្រះរាជាណាចក្រកម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់ នឹងដើម្បីទទួលអនុវត្ត

សម្រេច

ប្រការ ១ : ភ្នាក់ងារត្រួតពិនិត្យឱសថនៅតាមព្រំដែនមានមុខងារសំខាន់ក្នុងការត្រួតពិនិត្យការអនុវត្តន៍ បណ្តាបទដ្ឋាន ក្បួនច្បាប់ដែលពាក់ព័ន្ធនឹងសកម្មភាពនាំចូល នាំចេញផលិតផលឱសថសំដៅ ធានាគុណភាពឱសថនាំចូលនិងរាំងស្កាត់ការហូរចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា នូវផលិតផលឱសថដែលគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ ២ : មុខទំនិញដែលមានក្នុងកម្មវត្ថុនៃការត្រួតពិនិត្យរបស់ក្រសួងសុខាភិបាល រួមមាន ÷

- ឱសថសម័យនិងបូរាណគ្រប់ប្រភេទ
- វត្ថុធាតុដើម សំរាប់ផលិតកម្មឱសថ
- សំភារៈបរិក្ខារពេទ្យ និង សំភារៈបរិក្ខារ ប្រតិករមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ឱសថសាស្ត្រ
- ឈាម និង ផលិតផល ដែលបានមកពីឈាម
- សេរ៉ូម វ៉ាក់សាំង
- គ្រឿងញៀនតារាង I - II -III និង IV ដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន
- គ្រឿងសំអាង និងផលិតផលអានាម័យ ដែលផ្សំឡើងដោយមានជាតិសកម្ម ឱសថ។

ប្រការ ៣ : ក្រុមភ្នាក់ងារត្រួតពិនិត្យឱសថ ជាផ្នែកមួយស្ថិតនៅក្រោមឱវាទរបស់ក្រសួងសុខាភិបាលមានទី ចាត់ការកណ្តាលនៅក្នុងនាយកដ្ឋានឱសថនិងផ្គត់ផ្គង់ ។

៧ - ទីស្តីការក្រសួង សង្គមកិច្ចការងារ និង អតីតយុទ្ធជន

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាស លេខ : ០០៩ គក.ពក

គណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញសេចក្តីសំរេចលេខ១៥ សសរ ចុះថ្ងៃទី ០២-០២-១៩៩៥ របស រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការ រៀបចំទិវាកីឡាជន ពិការ
- បានឃើញប្រកាសលេខ ៧១ សកអ. ចុះថ្ងៃទី ១០-០២-១៩៩៥ របស់ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ស្តីពីការតែងតាំងឯកឧត្តម **ហ៊ុន លីហួត** អនុរដ្ឋលេខាធិការក្រសួង សង្គមកិច្ចការងារ និង អតីត យុទ្ធជន ជាប្រធានគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា
- យោងប្រកាសលេខ ០០៥ គក.ពក ចុះថ្ងៃទី ០១-០២-១៩៩៦ ស្តីពីបង្កើត លេខាធិការដ្ឋាន និង អនុគណៈកម្មការប្រតិបត្តិ
- យោងប្រកាសលេខ ០០៦ គក.ពក ចុះថ្ងៃទី ០២ -០២ - ១៩៩៦ ស្តីពី ការបែងចែកភារកិច្ច ដល់សមាជិកតំណាងអន្តរក្រសួង នៃគណៈកម្មការ រៀបចំទិវាកីឡាជនពិការកម្ពុជា

- យោងតាមស្មារតីអង្គប្រជុំ គណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ថ្ងៃទី ០៧-០២-១៩៩៦

សម្រេច

ប្រការ ១ : រៀបចំអធិបតីកិត្តិយសរួមមាន ÷

១-ឯកឧត្តម ស៊ុយ សែម រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

២-ឯកឧត្តម ហុង ថែម អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

៣-ជំទាវ នួន សួគ៌ា អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

ភារកិច្ច :

ជួយផ្តល់យោបល់សំរេចសំរបសំរួលរាល់ករណីទាំងឡាយ នៃគណៈកម្មការរៀបចំទិវាកីឡាជន ពិការកម្ពុជា ។

ប្រការ ២ : រៀបចំសមាជិកកិត្តិយសរួមមាន ÷

១-លោក មីវ ចឿង ប្រធានមន្ទីរ ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

២-លោក ទូច សាម៉ុន អនុប្រធាននាយកដ្ឋានចូលនិវត្តន៍ សង្គ្រោះសង្គម ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

៣-លោក កែវ សឿន ប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

៤-លោក ហ៊ុយ ហានសុង ប្រធាននាយកដ្ឋានពេទ្យការងារ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

៥-លោក ហាំង ស៊ីថា ប្រធាននាយកដ្ឋានអធិការកិច្ច ការងារ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

៦-លោក ថាច់ សែម ប្រធាននាយកដ្ឋានសន្តិសុខសង្គម ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

៧-លោក ឃឹម សន ប្រធាននាយកដ្ឋានមុខរបរ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

៨-លោក វង្ស វណ្ណា ប្រធាននាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

៩-លោក គង់ សារា ប្រធាននាយកដ្ឋានជនពិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

ភារកិច្ច :

ជួយផ្តល់យោបល់ និង ជួយផ្តល់សមាសភាពមន្ត្រីរាជការ ក្រោមឱវាទជួយដល់គណៈកម្មការលេខាធិការដ្ឋាន អនុគណៈកម្មការប្រតិបត្តិ ដែលមានការខ្វះខាត ។

ប្រការ ៣ : រៀបចំសមាសភាព និង ភារកិច្ចទីប្រឹក្សា នៃគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ÷

១- ឧត្តមសេនីយ៍ ទុំ សំបុរ ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ទីប្រឹក្សាសហអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ជាទីប្រឹក្សានៃគណៈកម្មការរៀបចំទិវាកីឡា ជនពិការកម្ពុជាជួយផ្តល់យោបល់ដល់គណៈកម្មការ និង ធ្វើការទំនាក់ទំនងជាមួយនឹង អគ្គលេខាធិការគណៈបក្ស ហ៊្វុនស៊ិនប៉ិចអំពាវនាវអញ្ជើញចូលរួមធ្វើវិភាគទានសប្បុរសធម៌ នៃ សមាជិកសមាជិកាគណៈបក្ស ។

២- ឧត្តមសេនីយ៍ មល រឿប ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ ទីប្រឹក្សាសហអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ជាទីប្រឹក្សាគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជាជួយផ្តល់យោបល់ដល់គណៈកម្មការ និង ធ្វើការទំនាក់ទំនងជាមួយនឹង អគ្គលេខា

ធិការគណៈបក្សប្រជាជនកម្ពុជាអំពាវនាវអញ្ជើញចូលរួមធ្វើវិភាគទានសប្បុរសធម៌នៃសមាជិក សមាជិកា នៃគណៈបក្ស ។

៣- ឯកឧត្តម ព្រាប តាន់ នាយការិយាល័យទី ៥ នៃអគ្គសេនាធិការ កងយោធពល ខេមរភូមិន្ទ ជាទីប្រឹក្សាគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ជួយផ្តល់យោបល់ដល់គណៈកម្មការ និង ធ្វើការទំនាក់ទំនង ក្នុងអគ្គសេនាធិការកងយោធពល ខេមរភូមិន្ទ ភូមិភាគ តំបន់ប្រតិបត្តិការសឹក រង អំពាវនាវ អញ្ជើញចូលរួមធ្វើវិភាគទានសប្បុរសធម៌ នៃនាយទាហាន នាយទាហានរង និងពលទាហាន ក្នុងកងយោធពលខេមរភូមិន្ទ ។

៤- ឧត្តមសេនីយ៍ ម៉ៅ ប៊ុន ណារិន ប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងមហាផ្ទៃ ជាទីប្រឹក្សាគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ជួយផ្តល់យោបល់ដល់គណៈកម្មការ និងធ្វើការទំនាក់ទំនងក្នុងអគ្គនាយកដ្ឋាននគរបាលជាតិ គ្រប់ស្នងការទាំងអស់ អំពាវនាវ អញ្ជើញចូលរួម ធ្វើវិភាគទានសប្បុរសធម៌ នៃនគរបាលជាតិ ។

៥- ឯកឧត្តម អ៊ូ គឹមស៊ន អនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអោយ ទីស្តីការគណៈរដ្ឋមន្ត្រី ជាទីប្រឹក្សាជួយផ្តល់យោបល់ដល់គណៈកម្មការធ្វើការទំនាក់ទំនងទៅ នឹងក្រសួងស្ថាប័ននានាក្នុងរាជរដ្ឋាភិបាល អំពាវនាវអញ្ជើញចូលរួមធ្វើវិភាគទានសប្បុរសធម៌ នៃមន្ត្រីរាជការ ។

៦- ឯកឧត្តម ស្រី វណ្ណផុង ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ ជាទីប្រឹក្សា ជួយផ្តល់យោបល់ដល់គណៈកម្មការធ្វើការអំពាវនាវអញ្ជើញចូលរួម ធ្វើវិភាគទានសប្បុរសធម៌ នៃក្រុមហ៊ុនសហគ្រាសទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

៧- លោក បូរិទ្ធី លន់ ជាទីប្រឹក្សាជួយផ្តល់យោបល់ដល់គណៈកម្មការធ្វើការទំនាក់ទំនងទៅនឹងអង្គការក្រៅរដ្ឋាភិបាលនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើវិភាគទានអញ្ជើញ ចូលរួមសប្បុរសធម៌ នៃអង្គការទាំងនោះ ។

៨- លោក ស៊ី សុផុន តំណាងអង្គការ NGO និងក្រុមហ៊ុន ជួយផ្តល់យោបល់ដល់ គណៈកម្មការធ្វើការទំនាក់ទំនងជាមួយអង្គការ NGO ក្រៅប្រទេស និងក្រុមហ៊ុនអញ្ជើញចូលរួមធ្វើវិភាគទានសប្បុរសធម៌ នៃអង្គការ និងក្រុមហ៊ុននានា ។

ប្រការ ៤ : បំពេញបន្ថែមភារកិច្ចដល់ ÷

– លោក ឡាក់ សំអាត អនុប្រធាន នៃគណៈកម្មការធ្វើការរៀបចំស្តង់តាំងពិព័រណ៍លក់ដូរក្នុងពហុកីឡាដ្ឋានជាតិអូឡាំពិក ជាមួយអនុប្រធានគណៈកម្មការហិរញ្ញវត្ថុក្នុងរយៈ ពេល ០៣ ថ្ងៃ គឺថ្ងៃ ២២-២៣-២៤ ខែ មីនា ឆ្នាំ ១៩៩៦ នេះ ។ ធ្វើការអំពាវនាវដល់ពាណិជ្ជករទាំងអស់អោយចូលរួមមកលក់ដូរឬតាំងពិព័រណ៍ឃោសនាលើមុខទំនិញរបស់ខ្លួន ។

–លោក កូវ គង់ តំណាងសាលាក្រុងភ្នំពេញ

–លោក ជា សន ប្រធានអធិការដ្ឋានសង្គមកិច្ច និងអតីតយុទ្ធជន រាជធានីភ្នំពេញ

–លោក លឹម អ៊ែលឡាង អនុគណៈកម្មការខ្ទឹមសារ រៀបចំបដាពាក្យស្លោកចែកផ្លូវ ថ្វាយអោយក្រុមហ៊ុនធ្វើ ហើយចែកគ្នាចងតាមផ្លូវក្នុងពហុកីឡាដ្ឋានជាតិអូឡាំពិក ។ សុំសិស្ស និស្សិត ប្រជាពលរដ្ឋក្រុងភ្នំពេញ ចូលរួមក្នុងកម្មវិធី ។

ប្រការ ៥ : រៀបចំលេខាធិការដ្ឋាន នៃគណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា **សមាសភាព** :

១-លោក គង់ ថាន់	អនុប្រធានមន្ទីរក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន	ប្រធាន
២–លោក គង់ សារ៉ា	ប្រធាននាយកដ្ឋានពិការ	អនុប្រធាន
៣–លោក កែវ គឹមថុន	អនុប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម	សមាជិក
៤–លោក ទៀវ សុគន្ធ	អនុប្រធានមន្ទីរ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន	សមាជិក
៥–លោក ទី ស៊ីថន	ប្រធានការិយាល័យរដ្ឋបាល, ស.ក.អ	សមាជិក

៦–លោក លក គឹមសាន អធិការរងនៃអធិការដ្ឋានសង្គមកិច្ចការងារនិង អតីតយុទ្ធជន សមាជិក

៧–លោក ម៉ែន រុន ការិយាល័យអន្តរជាតិ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន សមាជិក

៨–លោក ហៀង វាសនា ការិយាល័យអន្តរជាតិ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន សមាជិក

៩–លោក គួន ដានី ការិយាល័យអធិការកិច្ច ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន សមាជិក

១០–ណូ សំបុក តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការ អន្តរជាតិ សមាជិក

ប្រការ ៦ : រៀបចំអនុគណៈកម្មការប្រតិបត្តិទាំង ៦ នៃគណៈកម្មការរៀបចំទិវាកីឡាជន ពិការកម្ពុជា ÷

អនុគណៈកម្មការបច្ចេកទេស :

សមាសភាព :

១–លោក មាស សារិន ប្រធាននាយកដ្ឋានពហុកីឡាដ្ឋានជាតិអូឡាំពិក ប្រធាន

២–លោក សូ សាមុត តំណាងក្រសួងអប់រំយុវជន និង កីឡា អនុប្រធាន

៣–លោក សាមីឌី ស៊ីវឡូនា តំណាងសហព័ន្ធកីឡាកម្ពុជា អនុប្រធាន

៤–លោក យ៉ែម ឧត្តម តំណាងពហុកីឡាដ្ឋានជាតិអូឡាំពិក សមាជិក

៥–លោក ព្រំ ប៊ុនយី តំណាងពហុកីឡាដ្ឋានជាតិអូឡាំពិក សមាជិក

៦–វរៈសេនីយ៍ ទិត្យ ម៉េងឡុង ប្រធានមជ្ឈមណ្ឌលបំប៉នសុខភាព យោធិន ពិការ (គៀនស្វាយ) សមាជិក

៧–លោក ម៉ិល កាដូ តំណាងសហព័ន្ធកីឡាជនពិការកម្ពុជា សមាជិក

៨–លោក សុន សុងហាក តំណាងនាយកដ្ឋានប្រតិបត្តិអង្គការជនពិការកម្ពុជា សមាជិក

៩–លោក ហួន ហេន តំណាងអង្គការ អេ អេ អរ ស៊ី ស៊ី សមាជិក

១០–លោក សុង សុជាតិ តំណាងអង្គការ ស៊ីម៉ាក សមាជិក

១១–លោក ប៊ុត ប៊ូរី តំណាងអង្គការមារីណុល សមាជិក

១២–លោក សយ ស៊ើង តំណាងអង្គការ វី អាយ សមាជិក

១៣–លោក នៅ សំណាង តំណាងអង្គការ វី វី អេ អេហ្វ អាយ សមាជិក

១៤–លោក ពិត សុខ តំណាងអង្គការកម្ពុជា ត្រឹស្ត សមាជិក

១៤–អ្នកស្រី ជិល អុល តំណាងអង្គការ ឌី ភី អាយ សមាជិក

ខ - អនុគណៈកម្មការហិរញ្ញវត្ថុ :

សមាសភាព :

១–លោក ដួង ហ៊ុង អនុប្រធានមន្ទីរ ក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ប្រធាន

២–លោក ទួត ប៊ុនឡុង ប្រធានការិយាល័យក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន អនុប្រធាន

៣–លោក មាស សារឿន តំណាងអង្គការជនពិការកម្ពុជា សមាជិក

៤–លោក វិលី ស្រ៊ុន ប្រធានអង្គការ ធី អូ សមាជិក

គ - អនុគណៈកម្មការពិធីការនិងទំនាក់ទំនងសាធារណៈ ៖

សមាសភាព :

១–លោក ជា សុខុម តំណាងគណៈកម្មការបុណ្យជាតិ អន្តរជាតិ ប្រធាន

២–លោក សាន សំប៊ូរី តំណាងក្រសួងពត៌មាន អនុប្រធាន

៣–លោក ស៊ឹម សារ៉ាក់ តំណាងក្រសួងវប្បធម៌ សមាជិក

៤–លោក ទិត្យ សារុំនរ៉េត តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៥–លោក ពៀម វាលី តំណាងគណៈកម្មការបុណ្យជាតិ អន្តរជាតិ សមាជិក

៦–លោក ហែម ថុន តំណាងពហុកីឡាដ្ឋានជាតិអូឡាំពិក សមាជិក

៧–លោក កែន ស៊ីហួត តំណាងពហុកីឡាដ្ឋានជាតិអូឡាំពិក សមាជិក

៨–លោក កូវ គង់ តំណាងសាលាក្រុងភ្នំពេញ សមាជិក

៩–លោក ជា សុវណ្ណា តំណាងក្រសួងវប្បធម៌ សមាជិក

១០–លោក ទេស ហេង តំណាងគណៈកម្មការបុណ្យជាតិ និងអន្តរជាតិ សមាជិក

ឃ - អនុគណៈកម្មការរក្សាសន្តិសុខ :

សមាសភាព :

១–ឧត្តមសេនីយ៍ គង់ សារ៉ាន់ តំណាងនគរបាលរាជធានីភ្នំពេញ ប្រធាន

២–ឧត្តមសេនីយ៍ នាម អៀង តំណាងកងរាជអាវុធហត្ថ រាជធានីភ្នំពេញ អនុប្រធាន

៣–ឧត្តមសេនីយ៍ ភុំ ប៊ុនថន តំណាងក្រសួងការពារជាតិ អនុប្រធាន

៤–ឧត្តមសេនីយ៍ រស់ សុវណ្ណ តំណាងក្រសួងមហាផ្ទៃ អនុប្រធាន

ង - អនុគណៈកម្មការសង្គ្រោះបន្ទាន់ :

សមាសភាព :

១–លោក ជា សំណាង តំណាងក្រសួងសុខាភិបាល ប្រធាន

២–លោក មូ ស៊ន តំណាងនាយកដ្ឋានពេទ្យការងារ ស.ក.អ អនុប្រធាន

៣–លោក ម៉ែន នរិន្ទ តំណាងសុខាភិបាល អនុប្រធាន

ច - អនុគណៈកម្មការខ្ទឹមសារ :

សមាសភាព :

១-លោក លឹម អ៊ែល្យ៉ាផូ	អនុប្រធានមន្ទីរ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន	ប្រធាន
២-លោក គន់ យ៉ាន	តំណាងវិទ្យុជាតិ	អនុប្រធាន
៣-លោក អ៊ីវ បណ្ណសិទ្ធ	តំណាងទូរទស្សន៍ជាតិ	អនុប្រធាន
៤-លោក មាស ឈាន	តំណាងនាយកដ្ឋានជនពិការ ស.ក.អ	សមាជិក
៥-លោក ឡុង សុជាតិ	តំណាងនាយកដ្ឋានជនពិការ	សមាជិក
៦-លោក ហុង ហ៊ាន	តំណាងនាយកដ្ឋានជនពិការ	សមាជិក
៧-លោក គីម ហុង	តំណាងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន	សមាជិក
៨-លោក យិប ថាវិទ្ធិ	តំណាងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន	សមាជិក
៩-លោក អ៊ុង គៀនហេង	តំណាងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន	សមាជិក
១០-កញ្ញា ជុំ ស៊ីណាត	តំណាងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន	សមាជិក
១១-កញ្ញា ពិន មុន្នី	តំណាងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន	សមាជិក

ប្រការ ៧ : លេខាធិការដ្ឋាន និង អនុគណៈកម្មការប្រតិបត្តិទាំង ៦ ត្រូវអនុវ[illegible]ានល្អ នូវតួនាទី និងភារកិច្ចដែលបានកំណត់ទុកក្នុងប្រកាសលេខ ០០៥ [illegible] ចុះថ្ងៃទី០១ កុម្ភៈ ១៩៩៦ របស់គណៈកម្មការរៀបចំទិវាកីឡាជនពិការកម្ពុជា ។

ប្រការ ៨ : កំណត់យកថ្ងៃសុក្រទី ២២ សៅរ៍ទី ២៣ អាទិត្យទី២៤ ខែ មីនា ឆ្នាំ ១៩៩៦ ជាទិវាកីឡាជនពិការកម្ពុជា ប្រចាំឆ្នាំ ១៩៩៦ ។

ប្រការ ៩ : អធិបតីកិត្តិយស សមាជិកកិត្តិយស ទីប្រឹក្សា លេខាធិការ អនុគណៈកម្មការប្រតិបត្តិ ចូលរួមក្នុងកម្មវិធីតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការរៀបចំ ទិវាកីឡាជនពិការកម្ពុជា ។

ប្រការ ១០ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ - គណៈកម្មការរៀបចំទិវាកីឡាកម្ពុជា

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន លីហួត

* * *

៨ - ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

ប្រកាសលេខ ០១៣ បទ -ប្រក

ស្តីអំពីការប្រើប្រាស់ប្លង់អោយលេខទូរស័ព្ទជាតិ

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃ ០១/១១/៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា។

- បានឃើញអនុក្រឹត្យលេខ ០៥ អ ន ក្រ ចុះថ្ងៃទី ៥/០៣/១៩៨៧ ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍។
- បានឃើញសំនូមពរចុះថ្ងៃទី ០២/០២/១៩៩៦ របស់នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ។
- បានឃើញសំនូមពរចាំបាច់

សេចក្តីសំរេច

ប្រការ ១ : អនុញ្ញាតការប្រើប្រាស់គំរោងលេខ CMB/93/006 ផ្នែកមួយក្នុង «ប្លង់មេ» ដែលរៀបចំឡើងដោយជំនួយសហប្រតិបត្តិការនៃអង្គការ ITU/UNDP សំរាប់ជា«ប្លង់អោយលេខទូរសព្ទ័ជាតិចល័ត» តាមប្រការជាបន្តបន្ទាប់ដូចខាងក្រោម÷

១.១ បណ្តាញទូរសព្ទ័ចល័តនិង អចល័ត និងទូរសព្ទ័ឥតប្រើខ្សែក្នុងតំបន់ក្រុងភ្នំពេញ និង បណ្តាខេត្ត បច្ចុប្បន្នកំពុងបំរើសេវា ត្រូវរៀបបញ្ចូលតាម «ប្លង់អោយលេខ» ដោយព្រមៗគ្នាតាមសេចក្តីជូន ដំណឹងរបស់ក្រសួង ប,ទ ។

១.២ លេខពិសេស ឬសេវាពិសេសទាំងឡាយ ជាអាទ៍ សេវាទូរសព្ទ័ការីត្រូវកំណត់ដោយឡែក ដោយក្រសួងប.ទ និងក្រោយពេល «ប្លង់មេ» បានសំរេច ។

១.៣ សេវាវិទ្យុលេខសញ្ញាសេវាបរិមូល (value added service) និងសេវាថ្មី ។ ដទៃទៀត និង ត្រូវកំណត់ដោយក្រសួង ប.ទ នៅពេលក្រោយ ។

ប្រការ ២ : ប្លង់អោយលេខទូរសព្ទ័ជាតិ កំណត់ចំនួនខ្ទង់ ឬប្រវែងខ្ទង់លេខចំនួន «ប្រាំបីខ្ទង់»ជាលេខទូរសព្ទ័ជាតិ (Natoinal significant Number)គឺ «ពីរខ្ទង់» ជាលេខកូដតំបន់ ឬ ជាលេខកូដការី និង «ប្រាំមួយខ្ទង់»ជាលេខទូរសព្ទ័ ។

២.១ លេខកូដការី ត្រូវប្រើសំរាប់ហៅលេខទូរស័ព្ទចល័តក្នុងប្រព័ន្ធជាមួយគ្នា ។ ប្រព័ន្ធនីមួយៗដែលមានសេវាតាមខេត្តហើយត្រូវស្គាល់នាមជុំមណ្ឌលទូរសព្ទ័ចលត័សំរាប់តំបន់នោះ ។

២.២ ហៅទូរសព្ទ័ពីប្រពន្ធ័ទូរស័ព្ទ ចល័តមួយទៀតត្រូវហៅលេខកូដ «0» លេខកូដការី និងលេខទូរសព្ទ័ ចលត័ ។

ប្រការ ៣ : ការគិតថ្លៃសន្ទនាការទូរសព្ទ័ សន្ទនាក្នុងក្រុង ក្នុងតំបន់ ឆ្លងតំបន់ ... សន្ទនា អន្តរជាតិ ត្រូវផ្អែកតាមលេខទូរសព្ទ័អ្នកហៅនិងអ្នកទទួល ដែលមានស្ថានភាពក្នុងប្លង់អោយលេខទូរសព្ទ័ជាតិ ។

៣.១ ភាពចល័តនៃសេវាទូរសព្ទ័ចលត័ និង ត្រូវបានកំណត់ដោយខ្សែក ដោយក្រសួង ប. ទ ។

៣.២ សន្ទនាការទូរសព្ទ័ឆ្លងបណ្តាញ ឬ ឆ្លងប្រពន្ធ័ និង ត្រូវបានកំណត់ដោយក្រសួង ប. ទ តាមប្រភេទជាក់ស្តែង ។

ប្រការ ៤ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណៈនេយ្យ និង ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ នាយកដ្ឋានប្រៃសណីយ៍ គ្រប់មន្ទីរ ប.ទខេត្តក្រុង បណ្តាញក្រុមហ៊ុនសេវាទូរសព្ទ័ បណ្តាក្រុមហ៊ុនវិទ្យុលេខសញ្ញា ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សូ ឃុន

* * *

តារាងសង្ខេបនៃលេខតំបន់សំរាប់ប្រើក្នុងប្រព័ន្ធទូរស័ព្ទ

ខេត្ត	លេខតំបន់សំរាប់ប្រើ ជាមួយទូរស័ព្ទអចល័ត	លេខទូរស័ព្ទចល័ត Samart	លេខទូរស័ព្ទចល័ត Tricelcam	លេខទូរស័ព្ទចល័ត Camtel
Banteay Meanchey	054	015 54x xxx	017 54x xxx	018 54x xxx
Battambang	053	015 53x xxx	017 53x xxx	018 53x xxx
Kampong cham	042	015 42x xxx	017 42x xxx	018 42x xxx
Kampong chhang	026	015 26x xxx	017 26x xxx	018 26x xxx
Kampong speu	025	015 25x xxx	017 25x xxx	018 25x xxx
Kampong Thom	062	015 62x xxx	017 62x xxx	018 62x xxx
Kampot	033	015 33x xxx	017 33x xxx	018 33x xxx
Kandal	024	015 24x xxx	017 24x xxx	018 24x xxx
Kep	036	015 36x xxx	017 36x xxx	018 36x xxx
Koh Kong	035	015 35x xxx	017 35x xxx	018 35x xxx
Kratie	072	015 72x xxx	017 72x xxx	018 72x xxx
Mondul Kiri	073	015 73x xxx	017 73x xxx	018 73x xxx
Phnom Penh	023	015 8xx xxx	017 8xx xxx	018 8xx xxx
Preah Vihear	064	015 64x xxx	017 64x xxx	018 64x xxx
Prey Veng	043	015 43x xxx	017 43x xxx	018 43x xxx
Pursat	052	015 52x xxx	017 52x xxx	018 52x xxx
Ratanak Kiri	075	015 75x xxx	017 75x xxx	018 75x xxx
Siem Reap	063	015 63x xxx	017 63x xxx	018 63x xxx
Sihanoukville	034	015 34x xxx	017 34x xxx	018 34x xxx
Rtung Treng	074	015 74x xxx	017 74x xxx	018 74x xxx
Svay Rieng	044	015 44x xxx	017 44x xxx	018 44x xxx
Takeo	032	015 32x xxx	017 32x xxx	018 32x xxx
Udor Meanchey	065	015 65x xxx	017 65x xxx	018 65x xxx

កំណត់ចំណាំ : លេខទូរស័ព្ទចល័តនៅតាមបណ្ដាខេត្តនឹងត្រូវចាប់ផ្ដើមដូរពីថ្ងៃទី ១មេសា ៩៦ទៅ

បោះពុម្ពនៅរោងពុម្ពធិស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១២៦០ រៀល